**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

# <u>សេចក្តីប្រកាសព័ត៌មាន</u>
# លទ្ធផលនៃកិច្ចប្រជុំកំពូលអាស៊ាន-អូស្ត្រាលី លើកទី១
# នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២១ តាមប្រព័ន្ធវីដេអូ

កិច្ចប្រជុំកំពូលបានកត់សម្គាល់នូវសមិទ្ធិផលប្រកបដោយអត្ថន័យនានា ដែលសម្រេចបានក្រោមទំនាក់ទំនងដៃគូសន្ទនាអាស៊ាន-អូស្ត្រាលី នារយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ និងបានទទួលស្គាល់ថា កិច្ចប្រជុំកំពូលអាស៊ាន-អូស្ត្រាលី លើកទី១ អាចនឹងជួយបើកទំព័រថ្មីនៃភាពជាដៃគូ ព្រមទាំងអាចជួយធ្វើឱ្យកាន់តែស៊ីជម្រៅ និងពង្រីកបន្ថែមទៀតកិច្ចសហប្រតិបត្តិការ រួមមានតាមរយៈការអនុវត្តផែនការសកម្មភាពអាស៊ាន-អូស្ត្រាលី (២០២០-២០២៤) ។ ថ្នាក់ដឹកនាំអាស៊ានបានឯកភាពបង្កើតឱ្យមានភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយមួយ រវាងអាស៊ាន និងអូស្ត្រាលី ដែលពោរពេញដោយអត្ថន័យ សំខាន់និងផ្តល់ផលប្រយោជន៍ទៅវិញទៅមក និងបានអះអាងជាថ្មីនូវការប្តេជ្ញាចិត្តរបស់ខ្លួន ដើម្បីធ្វើការជាមួយអូស្ត្រាលី ដើម្បីឱ្យភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយនោះមានប្រសិទ្ធភាព។

កិច្ចប្រជុំកំពូលបានគូសបញ្ជាក់ពីសារៈសំខាន់នៃតំបន់សេដ្ឋកិច្ចសេរីអាស៊ាន-អូស្ត្រាលី-នូវែលសេឡង់ (AANZFTA) និងបានប្តេជ្ញាចិត្តដើម្បីធានាថា តំបន់សេដ្ឋកិច្ចសេរីអាស៊ាន-អូស្ត្រាលី-នូវែលសេឡង់ (AANZFTA) នឹងនៅតែជាតំបន់ពាណិជ្ជកម្មសេរីអាស៊ានបូកមួយដែលគ្រប់ជ្រុងជ្រោយបំផុត និងមានគុណភាពខ្ពស់។ កិច្ចប្រជុំបានគូសបញ្ជាក់នូវការប្តេជ្ញាចិត្តឆ្ពោះទៅកាន់ការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ (RCEP) ដើម្បីកាច់ចង្កូតពាណិជ្ជកម្មតំបន់ និងជំរុញការស្តារឡើងវិញ។

ថ្នាក់ដឹកនាំអាស៊ានបានសម្តែងនូវការកោតសរសើរដល់ការគាំទ្ររបស់អូស្ត្រាលី ចំពោះវិធានការ និងគំនិតផ្តួចផ្តើមនានាពាក់ព័ន្ធនឹងជំងឺកូវីដ-១៩ របស់អាស៊ាន ក៏ដូចជាកិច្ចខិតខំប្រឹងប្រែងស្តារឡើងវិញ រួមមាន តាមរយៈការផ្តល់មូលនិធិចំនួន ៥២៣,២ លានដុល្លារអូស្ត្រាលី សម្រាប់គំនិតផ្តួចផ្តើមការទទួលបានវ៉ាក់សាំង និងសន្តិសុខសុខភាព។ ថ្នាក់ដឹកនាំអាស៊ានបានស្វាគមន៍ការប្តេជ្ញាចិត្តជាថ្មីរបស់អូស្ត្រាលី ក្នុងការផ្តល់ទឹកប្រាក់ជាង ១២០លានដុល្លារអូស្ត្រាលី ដល់គំនិតផ្តួចផ្តើមនានានៅពេលអនាគតរបស់អាស៊ាន ក្នុងរយៈពេល១០ឆ្នាំទៅមុខ ដែលបានប្រកាសដោយ **ឯកឧត្តម ស្កុត ម៉ារីសុន** (Scott Morrison) នាយករដ្ឋមន្ត្រីអូស្ត្រាលី ។ ថ្នាក់ដឹកនាំបានឯកភាពគ្នាក្នុងការផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងឡើងលើការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងវិស័យអាទិភាពនានា ដែល


អាសយដ្ឋានៈ លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

គាំទ្រដល់ការស្តារឡើងវិញយ៉ាងឆាប់រហ័សក្រោយពីជំងឺរាតត្បាត ដូចជា ការកែលម្អលទ្ធភាពសុខភាពសាធារណៈ ការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធ សេដ្ឋកិច្ចឌីជីថល ការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍធនធានមនុស្ស។

នាយករដ្ឋមន្ត្រីអូស្ត្រាលី បានអះអាងជាថ្មីដល់មេដឹកនាំអាស៊ាន នូវការប្តេជ្ញាចិត្តរបស់អូស្ត្រាលីចំពោះមជ្ឈភាពអាស៊ាន សន្តិភាពនិងសន្តិសុខតំបន់ រួមមានតាមរយៈការគាំទ្រដល់ទស្សនៈវិស័យអាស៊ាន ស្តីពីឥណ្ឌូ-ប៉ាស៊ីហ្វិក (AOIP) និងការប្រកាន់ខ្ជាប់យ៉ាងម៉ឺងម៉ាត់ចំពោះសន្ធិសញ្ញាស្តីពីការមិនរីកសាយភាយអាវុធនុយក្លេអ៊ែរ (NPT) ។ ថ្នាក់ដឹកនាំបានផ្លាស់ប្តូរទស្សនៈគ្នាទៅវិញទៅមកលើការវិវឌ្ឍថ្មីៗនៅក្នុងតំបន់ និងអន្តរជាតិ រួមមាន សម្ព័ន្ធភាពសន្តិសុខត្រីភាគីអូស្ត្រាលី-ចក្រភពអង់គ្លេស-សហរដ្ឋអាមេរិក (AUKUS) សារៈសំខាន់នៃការថែរក្សាសន្តិភាព និងសន្តិសុខនៅសមុទ្រចិនខាងត្បូង និងស្ថានការណ៍នៅប្រទេសមីយ៉ាន់ម៉ា ផងដែរ។

**សម្តេចតេជោនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់អំពីការរៀបចំជាប្រវត្តិសាស្ត្រនូវកិច្ចប្រជុំកំពូលអាស៊ាន-អូស្ត្រាលី ប្រចាំឆ្នាំលើកទីមួយ និងបានបញ្ជាក់ជាថ្មីនូវការគាំទ្ររបស់កម្ពុជាសម្រាប់ការបង្កើតភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយរវាងអាស៊ាន និងអូស្ត្រាលី។ **សម្តេចតេជោ** បានសាទរចំពោះការរួមចំណែកដ៏មានសារៈសំខាន់របស់អូស្ត្រាលី ក្នុងយុទ្ធនាការពហុភាគី ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ក៏ដូចជាការធ្វើឱ្យកំណើនសេដ្ឋកិច្ចក្នុងតំបន់រស់ឡើងវិញ ជាពិសេសតាមរយៈការដាក់ចេញនូវភាពជាដៃគូសម្រាប់យុទ្ធសាស្ត្រស្តារឡើងវិញជាមួយអាស៊ាន ដែលជាដៃគូមួយដ៏សំខាន់។ **សម្តេចតេជោ** បានលើកទឹកចិត្តអូស្ត្រាលីឱ្យគាំទ្របន្ថែមទៀតដល់កិច្ចខិតខំប្រឹងប្រែងកសាងសហគមន៍អាស៊ាន និងសមាហរណកម្មក្នុងតំបន់ តាមរយៈផែនការមេស្តីពីការតភ្ជាប់អាស៊ាន (MPAC) ឆ្នាំ ២០២៥ និងផែនការការងារនៃគំនិតផ្តួចផ្តើមសម្រាប់សមាហរណកម្មអាស៊ាន (IAI) ដំណាក់កាលទី៤។

ជាងនេះទៅទៀត **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានលើកទឹកចិត្តឱ្យអូស្ត្រាលីជួយបន្ថែមទៀតដល់ការពង្រឹងវិស័យអាទិភាពមួយចំនួន ដូចជា បច្ចេកវិទ្យាឌីជីថល និងពាណិជ្ជកម្មអេឡិចត្រូនិក សហគ្រាសខ្នាតមីក្រូ តូច និងមធ្យម (MSMEs) និងការអប់រំ ជាពិសេសការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈសម្រាប់ស្ត្រី និងពលករចំណាកស្រុកដែលបានវិលត្រឡប់វិញ ដើម្បីពួកគេអាចស្វែងរកការងារថ្មីបានធ្វើ និងមានជីវភាពកាន់តែល្អប្រសើរជាងមុន។

**សម្តេចតេជោនាយករដ្ឋមន្ត្រី** បានកោតសរសើរបន្ថែមទៀតចំពោះកិច្ចខិតខំប្រឹងប្រែងរបស់អូស្ត្រាលីក្នុងការលើកកម្ពស់សមភាពយេនឌ័រ ការពង្រឹងអំណាចសេដ្ឋកិច្ចស្ត្រី និងរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (WPS) ព្រមទាំងបានសម្តែងនូវការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការធ្វើការជាមួយអូស្ត្រាលីដើម្បីជំរុញបន្ថែមទៀតដល់វិស័យសំខាន់ៗទាំងនេះ៕

ថ្ងៃពុធ ៦រោច ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០២១